

# ខាល់ឌី និងពពែរាំរែក

Svay Leemeng

Seat Sopheap

Let's Read

The Asia Foundation



កាលពីព្រេងនាយ មានក្មេងគង្វាលពពែម្នាក់ ឈ្មោះខាល់ឌី និង ក្រុមគ្រួសារ រស់នៅក្នុងភូមិមួយ ក្នុងប្រទេសអេត្យូពី។ ពួកគេ តែងតែប្តូរទីលំនៅរៀងរាល់ពីរឬបីខែម្តង ដើម្បីរកស្មៅខ្ចីៗឱ្យហ្វូង ពពែស៊ី។



រាល់ព្រឹក ខាល់ឌីតែងតែទៅឃ្វាលពពែនៅលើភ្នំ ជាមួយ
មិត្តភក្តិដទៃទៀត។ រាល់ពេលត្រឡប់មកផ្ទះវិញ ពួកគេតែងតែ
អស់កម្លាំងជាខ្លាំង ហើយហ្វូងពពែក៏មិនស្វាហាប់ដែរ។



ថ្ងៃមួយ ខាល់ឌីនិងមិត្តភក្តិបាននាំហ្វូងពពែទៅស៊ីស្មៅខ្ចីនៅលើភ្នំនៅឯចុងភូមិ ហើយក៏ប្រទះឃើញមានអាស្រមមួយដែលមានព្រះសង្ឃគង់នៅទីនោះ។



នៅពេលដែលពួកគេកំពុងរវល់ប្រឡែងលេង ស្រាប់តែបាត់ហ្វូងពពែអស់ ។ ខាល់ឌី ភ័យណាស់ ខំដើរស្វែងរក ហ្វូងពពែគ្រប់ទីកន្លែង។



ស្រាប់តែពេលនោះ ខាល់ឌីបានឮសំឡេងពពែស្រែកយ៉ាង ខ្ញៀវខ្ញារ ។ ខាល់ឌីរត់ទៅតាមសំឡេងនោះ ក៏ឃើញហ្វូងពពែ កំពុងរាំជារង្វង់យ៉ាងស្វាហាប់។ មុនដំបូងខាល់ឌីមានអារម្មណ៍ ត្រេកអរណាស់ ដោយបានរកឃើញហ្វូងពពែវិញ។ តែគេបែរជា មានការងឿងឆ្ងល់ទៅវិញ ព្រោះឃើញពពែមានកម្លាំងខ្លាំង ប្លែក ខុសពីធម្មតា ។



ដោយសារអស់កម្លាំងខ្លាំងពេក ខាល់ឌីក៏សម្រាកក្រោម
ដើមឈើសម្លឹងមើលហ្វូងពពែទាំងឡើងឆ្វល់។



គេសង្កេតឃើញពពែកំពុងស៊ីគ្រាប់ពណ៌ក្រហមឆ្នៅពីគុម្ពឈើមួយដែលមានស្លឹកភ្លឺថ្លា បន្ទាប់មកពួកវាកញ្ជ្រោល ហើយស្រែកយ៉ាងរីករាយ។



ខាល់ឌីមិនអស់ចិត្ត ក៏បានបេះផ្លែនោះមកទំពា ។ ភ្លាមៗ
នោះ ខាល់ឌីក៏មានកម្លាំងស្វាហាប់ឡើងវិញ ទើបគេបេះគ្រាប់
ពណ៌ក្រហមនោះទុក ។



តាមផ្លូវចុះពីភ្នំវិញ ខាល់ឌីក៏នឹកឃើញដល់ព្រះសង្ឃមួយអង្គ
ដែលគង់នៅក្នុងអាស្រម ហើយក៏បានប្រគេនផ្លែពណ៌ក្រហម
នោះទៅព្រះអង្គ។



ខាល់ឌីបានយកផ្លែនោះ ទៅដំឱ្យក្លាយជាបំណែកតូចល្អិត ហើយឆុងជាមួយទឹកក្តៅ ដើម្បីប្រគេនព្រះសង្ឃ ។ ក្រោយឆាន់រួច ព្រះសង្ឃមានសង្ឃដីកាថា៖ ”អាត្មាមានកម្លាំងវិញហើយ ។ អាត្មាចម្រើនពរចៅ។”



មកដល់ផ្ទះវិញ ខាល់ឌីបានហាលផ្លែពណ៌ក្រហមនោះឱ្យក្រៀម រួចកិនឱ្យម៉ត់ និងយកទៅប្រគេនព្រះសង្ឃដទៃទៀតក្នុងភូមិ ។



ក្រោយពីឆាន់ទឹកឆុងជាមួយផ្លែពណ៌ក្រហមនោះ ព្រះសង្ឃគ្រប់អង្គអាចធ្វើសម្មាធិរហូតដល់យប់ជ្រៅដោយចិត្តស្ងប់ ហើយចាត់ទុកផ្លែពណ៌ក្រហមនោះ ជាការរកឃើញដ៏អស្ចារ្យមួយ។



ខាល់ឌី សប្បាយចិត្តណាស់ដែលបានស្គាល់ផ្លែដ៏អស្ចារ្យនេះពី ហ្វូងពពែ ។ គេបានចែកផ្លែពណ៌ក្រហមនោះទៅឱ្យអ្នកភូមិរបស់ គេគ្រប់ៗគ្នា។



ចាប់ពីថ្ងៃនោះមក អ្នកភូមិតែងតែនាំគ្នាទៅបេះផ្លែពណ៌ក្រហមនោះ យកមកធ្វើជាភេសជ្ជៈផឹករាល់ពេលដែលពួកគេធ្វើការអស់កម្លាំង ឬមានអារម្មណ៍តានតឹង ហើយក៏បានដាក់ឈ្មោះឱ្យផ្លែពណ៌ក្រហមនោះថា "កាហ្វេ" ។ ក្រោយមក គ្រាប់ពូជផ្លែកាហ្វេទាំងនោះត្រូវបានដាំដុះ និងចែកចាយតៗគ្នាទូទាំងពិភពលោក។



សហព័ន្ធសាធារណរដ្ឋប្រជាធិបតេយ្យអេត្យូពី ស្ថិតនៅក្នុងទ្វីបអាហ្វ្រិក មានផ្ទៃដី ១ ១០០ ០០០ គីឡូម៉ែត្រការ៉េ និងមានប្រជាជនចំនួន ១០២ លាននាក់។ រដ្ឋធានី និងទីក្រុងដែលធំជាងគេឈ្មោះ អាឌីស អាបាបា (Addis Ababa)។ អេត្យូពីមានព្រំប្រទល់ជាប់នឹងប្រទេស កេនយ៉ា អេរីត្រេ ហ្ស៊ីប៊ូទី សូម៉ាលី និងប្រទេសស៊ូដង់។

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*ខាល់ឌី និងពពែរាំរែក (Kaldi and the Dancing Goats)*, Author: Svay Leemeng. Illustrator: Seat Sopheap. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/